**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២

លេខ: ០៥ ប្រ.ក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងគ្រឿងពិនិត្យភាពយន្ត និងវីដេអូ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ១:** ប្រកាសនេះមានគោលបំណងគ្រប់គ្រងអាជីវកម្ម សេវាកម្មថតរូប ផ្តិតរូប និងថតវីដេអូ ដើម្បីធានាឲ្យបាននូវការគោរពសិទ្ធិ ទំនៀមទម្លាប់ប្រពៃណី និង សីលធម៌របស់សង្គមជាតិ។

**ប្រការ២:** អាជីវកម្ម សេវាកម្មថតរូប ផ្តិតរូប និងថតវីដេអូ សំដៅអាជីវកម្មដែលប្រើប្រាស់ឧបករណ៍ចាប់យករូបភាព ឬនិងសំឡេង រួមបញ្ចូលបច្ចេកទេសសិល្បៈ និងដោយមានការរៀបចំទុកជាមុន ដើម្បីបង្កើតនូវសោភ័ណភាពរូបភាព សម្រាប់បម្រើឲ្យគោលបំណង ឬគំនិតមួយ។

**ប្រការ៣:** រូបថតសិល្បៈ ជាកម្មសិទ្ធរបស់ម្ចាស់រូប ។ ការយករូបថតសិល្បៈទៅប្រើប្រាស់ ក្នុងទិសដៅអ្វីក៏ដោយ ត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ។

រូបថតសិល្បៈ មិនរាប់បញ្ចូល ការថតនូវរូបភាព ឬ សកម្មភាពរបស់បុគ្គល ឬ ក្រុមណាមួយដោយគ្មានការរៀបចំទុកជាមុន សម្រាប់បម្រើឲ្យការផ្សព្វផ្សាយពត៌មាន នោះឡើយ។

**ប្រការ៤:** រាល់ការប្រើប្រាស់បច្ចេកទេស កាត់តរូបភាព លើរាងកាយបុគ្គល ដើម្បីបង្កើតជារូបភាពមួយផ្សេងដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល ទំនៀមទម្លាប់ប្រពៃណីជាតិ និងជំនឿសាសនា ត្រូវហាមឃាត់។

អាជីវករ សេវករ: ថតរូប ផ្តិតរូប និងថតវីដេអូ មិនត្រូវប្រើប្រាស់សកម្មភាពរបស់ខ្លួនធ្វើឲ្យខូចខាត ឬ ប៉ះពាល់ដល់របៀបរបបក្នុងពិធីជាប្រពៃណី លើកលែងតែមានការយល់ព្រមពីម្ចាស់ពិធីនោះ។

**ប្រការ៥:** រូបថតសិល្បៈគ្រប់ប្រភេទ អាចប្រើប្រាស់ សម្រាប់ការផ្សព្វផ្សាយ ជាសាធារណៈបាន ប្រសិនបើរូបភាពនោះ មានតម្លៃសិល្បៈខ្ពស់ និងមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់។

ការផលិតរូបភាពអាសអាភាស ត្រូវហាមឃាត់។

**ប្រការ៦:** ការប្រកបអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ឬ ពីការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខ័ណ្ឌ ស្រុកគោលដៅ ដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

រាល់ការអនុញ្ញាត ប្រកបអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ ត្រូវមានកម្រៃសេវាកម្មដែលកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្ម របស់ការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខ័ណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៧:** នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ប្រធាននាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និង ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន " ដើម្បីជ្រាបជាព័ត៌មាន "
-គ្រប់សាលារាជធានី ខេត្ត" ដើម្បីសហការ "
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ